ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ១៨៥ សជណ.ទត

ថ្ងៃអង្គារ ៤កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពី

## វិធានការចាំបាច់ចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិកផ្នែកឯកជនក្នុងវិស័យទេសចរណ៍ក្នុងរាជធានីភ្នំពេញរយៈពេល ០៣ថ្ងៃ គឺចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១

យោងការជូនដំណឹងរបស់សាលារាជធានីភ្នំពេញអំពី "តារាងផែនការប្រចាំថ្ងៃសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិកវិស័យសុខាភិបាលឯកជន បុគ្គលិកអង្គការក្រៅរដ្ឋាភិបាលផ្តល់សេវាសុខាភិបាល ព្រះសង្ឃទាំងពីរគណៈ បុគ្គលិកផ្នែកឯកជនក្នុងវិស័យទេសចរណ៍ អាជីវករផ្សាររដ្ឋ-ឯកជន ក្រុមយុវជនជួរមុខ និងក្រុមសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលត្រូវចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ក្នុងរាជធានីភ្នំពេញ" ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ រដ្ឋបាលរាជធានីភ្នំពេញគ្រោងនឹងចាប់ផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិកផ្នែកឯកជនក្នុងវិស័យទេសចរណ៍រយៈពេល ០៣ថ្ងៃ (ថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១) នៅទូទាំងរាជធានីភ្នំពេញ។

ក្រសួងទេសចរណ៍យល់ឃើញថា នៅក្នុងអំឡុងពេលនៃការចុះឈ្មោះ និងពេលចាក់វ៉ាក់សាំង តែងមានអ្នកចូលរួមច្រើន ដែលជាឧបសគ្គនៃការប្រកាន់ខ្ជាប់នូវការរក្សាគម្លាតសុវត្ថិភាព អាស្រ័យហេតុនេះ ក្រសួងទេសចរណ៍សូមក្រើនរំលឹក និងសំណូមពរយ៉ាងទទូចដល់លោក លោកស្រី ម្ចាស់ ឬអ្នកគ្រប់គ្រងមូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ មេត្តាចូលរួមអនុវត្តតាមវិធានការចាំបាច់ដូចខាងក្រោម៖

១. ម្ចាស់មូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវបំពេញបញ្ជីឈ្មោះ និងព័ត៌មានរបស់បុគ្គលិកខ្លួន **(ដូចមានតារាងគំរូជូនភ្ជាប់)** និងភ្ជាប់មកជាមួយនូវអាជ្ញាបណ្ណទេសចរណ៍ **(ថតចម្លង)** រួចបញ្ជូនមកស្នើសុំការបញ្ជាក់ជាផ្លូវការពីមន្ទីរទេសចរណ៍រាជធានីភ្នំពេញ **(លេខទូរស័ព្ទទំនាក់ទំនង៖ ០៩២ ៧៦៦ ១៦៨)**។ បន្ទាប់ពីបានការបញ្ជាក់ជាផ្លូវការពីមន្ទីរទេសចរណ៍រាជធានីភ្នំពេញ ម្ចាស់មូលដ្ឋានអាជីវកម្មត្រូវបញ្ជូនបញ្ជីឈ្មោះបុគ្គលិកទៅរដ្ឋបាលខណ្ឌដែលអាជីវកម្មតាំងនៅ ដើម្បីស្នើសុំចុះឈ្មោះចាក់វ៉ាក់សាំង។

២. ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ និងដោយការទទួលខុសត្រូវ នូវវិធានការ "៣ការពារ ៣កុំ"។

៣. ម្ចាស់មូលដ្ឋានអាជីវកម្មទេសចរណ៍ទាំងអស់ ត្រូវធ្វើជាតំណាងសម្របសម្រួលដល់ការចុះឈ្មោះចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបុគ្គលិករបស់ខ្លួន ជៀសវាងការកកកុញនៅពេលទៅចុះឈ្មោះច្រើនគ្នា។

សម្រាប់ព័ត៌មានបន្ថែមលោក លោកស្រីអាចទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ៖ **០៨៩ ៧៦៧ ៦៦៤ - ០៩២ ៧៧ ៩៨ ៣៣ - ០១១ ៨៣៣ ៣១៨**។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមលោក លោកស្រីម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្មទេសចរណ៍ទាំងអស់ អនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ក្រសួងទេសចរណ៍

**ចម្លងជូន÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងសុខាភិបាល
- គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
- សាលារាជធានីភ្នំពេញ

  "ដើម្បីជូនជ្រាប"
- មន្ទីរទេសចរណ៍រាជធានីភ្នំពេញ
- គ្រប់សមាគមក្នុងឧស្សាហកម្មទេសចរណ៍
- ប្រតិបត្តិករ និងម្ចាស់អាជីវកម្មសេវាកម្មទេសចរណ៍

  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- ឯកសារ កាលប្បវត្តិ